ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ព្រហស្បតិ៍ ៦ រោច ខែ ភទ្របទ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោកជំទាវបណ្ឌិត Devyani Uttam Khobragade ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋឥណ្ឌាប្រចាំនៅប្រទេសកម្ពុជា

នាព្រឹកថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុញ្ញាតទទួលជួបសម្តែងការគួរសមជាមួយលោកជំទាវបណ្ឌិត **Devyani Uttam Khobragade** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌាប្រចាំនៅប្រទេសកម្ពុជា និងបានពិភាក្សាអំពីវិស័យជាអាទិភាពក្នុងក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ឥណ្ឌា ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន។

ជាមួយនឹងកិច្ចស្វាគមន៍ចំពោះជំនួបផ្ទាល់ជាមួយ**លោកជំទាវបណ្ឌិត Devyani Uttam Khobragade ឯកអគ្គរដ្ឋទូតឥណ្ឌា** និងថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌាដែលបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងជំនួយវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនចំពោះរាជរដ្ឋាភិបាលនាអំឡុងពេលមានការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកឡើងវិញផងដែរអំពីប្រវត្តិនៃចំណងមិត្តភាព, ប្រពៃណី, វប្បធម៌រវាងប្រជាជនកម្ពុជា និងប្រជាជនឥណ្ឌាតាំងពីយូរលង់ណាស់មកហើយ ស្តែងតាមរយៈសំណង់ប្រាសាទនានាមួយចំនួននៅប្រទេសកម្ពុជា ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** សង្ឃឹម និងជឿជាក់ថា ភាគីទាំងពីរនឹងបន្តជំរុញចំណងមិត្តភាពនេះឱ្យកាន់តែទទួលបាននូវផ្លែផ្កាបន្ថែមទៀតតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអាទិភាព ដើម្បីធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាប្រកបដោយចីរភាព ។

លោកជំទាវបណ្ឌិត **Devyani Uttam Khobragade** ឯកអគ្គរដ្ឋទូតឥណ្ឌា បានថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អនាពេលកន្លងមករវាង កម្ពុជា-ឥណ្ឌា និងបានអបអរសាទរចំពោះ **ឯកឧត្តមអគ្គបណ្ឌិត**

**សភាចារ្យ** ដែលទទួលបានការទុកចិត្តពីរាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា ។ ភាគីឥណ្ឌា សង្ឃឹមថា ក្នុងនីតិកាលថ្មីនេះ កម្ពុជា-ឥណ្ឌា នឹងបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀតលើវិស័យអាទិភាព របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនោះ ការបង្កើតឱ្យមានយន្តការសម្របសម្រួលដល់ដំណើរការពាណិជ្ជកម្ម និង វិនិយោគ តាមរយៈកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម និងការជំរុញការតភ្ជាប់រវាងប្រជាជន និងប្រជាជន តាមរយៈជើងហោះហើរត្រង់ឥណ្ឌា-កម្ពុជា ដែលរដ្ឋាភិបាលឥណ្ឌាគ្រោងដាក់ដំណើរការនាពេលឆាប់ៗខាងមុខ និងការតភ្ជាប់វិស័យឌីជីថល ជាដើម ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងក្តីរីករាយ និងគាំទ្រកិច្ចសហប្រតិបត្តិការ របស់រដ្ឋាភិបាលឥណ្ឌា ក្នុងការជំរុញកិច្ចសម្រួលពាណិជ្ជកម្មទ្វេភាគី សំដៅផ្តល់ប្រយោជន៍ទៅវិញទៅមករវាង កម្ពុជា-ឥណ្ឌា និងគាំទ្រចំពោះការបង្កើតឱ្យមានជើងហោះហើរត្រង់មកប្រទេសកម្ពុជា ដែលនឹងជំរុញការតភ្ជាប់ រវាងប្រជាជន និងប្រជនជន និងលំហូរទេសចរណ៍រវាងប្រទេសទាំងពីរ ។ ភាគីទាំងពីរនឹងពិនិត្យរួមគ្នាលើ ការតភ្ជាប់វិស័យឌីជីថល ដែលជាវិស័យអាទិភាពមួយក្រោមយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យច្បាស់លាស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សំដៅបន្តអភិវឌ្ឍលើគ្រប់វិស័យប្រកបដោយចីរភាព ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី,** ជាថ្មីម្តងទៀត, បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា ដែលបានបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ ទ្វេភាគីលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងជួយគាំទ្រដល់យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងប្រជាជនកម្ពុជា និងបានជូនពរ លោកជំទាវបណ្ឌិត Devyani Uttam Khobragade ឯកអគ្គរដ្ឋទូត និង សហការី ទទួលបានសុខភាពល្អ និងជោគជ័យ ក្នុងអាណត្តិការងាររបស់លោកជំទាវនៅប្រទេសកម្ពុជា ។